# ការប្រៀបធៀបកម្រិតនៃការពេញចិត្តចំពោះមុខវិជ្ជាសិក្សា របស់សិស្សមធ្យមសិក្សាៈ ការស្រាវជ្រាវបឋម

Comparing Levels of Subjects Satisfaction of High School Students: A Preliminary Study

*ដោយ : លោក* **ប៉ាន់ សំណាង**

*មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## ១.សេចក្តីផ្តើម

*ឪពុកម្តាយគ្រប់រូប មានកាតព្វកិច្ចបញ្ជូនកូនទៅសាលា ព្រោះការយកចិត្តទុកដាក់ដល់ការសិក្សារបស់កូន គឺជាកត្តាមួយសំខាន់នៅក្នុងសង្គមគ្រួសារ (ហៃយ ចម្ងង,២០១៩)។ ចំពោះការសិក្សាមធ្យមសិក្សា គឺផ្តោតលើការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្សានុសិស្សឱ្យប្រកបដោយ ចំណេះដឹង បំណិន និងជំនាញសតវត្សទី២១ និងមានសីលធម៌ ឥរិយាបថល្អ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់បន្តការសិក្សាទៅកម្រិតឧត្តមសិក្សា (ក្រសួងអប់រំ យុវជន និងកីឡា,២០២៤)។ ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្សនេះ ទាមទារនូវកត្តាជាច្រើន ដើម្បីបំពេញឱ្យបាន។*

*កម្មវិធីសិក្សា ត្រូវរៀបចំឱ្យឆ្លើយតបនឹងគោលបំណងនៃការបណ្តុះបណ្តាល។ ចំណុចនេះសម្រេចបាន អាស្រ័យលើការពេញចិត្តរបស់សិស្សានុសិស្សទៀតក្នុងការសិក្សា ព្រោះការពេញចិត្ត គឺជាគំនិតស្នេហ៍គ្រស្នាញដែលមានអត្ថន័យ និងការអនុវត្តច្រើន* (Elegba et al.,2017)*។ ពាក្យ«ពេញចិត្ត»មានន័យថា គាប់ចិត្ត, ស្ម័គ្រចិត្ត (ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០២២)។ ការណ៍នេះ ត្រូវបង្ហាញការបញ្ចេញមតិ និងការអនុវត្តយ៉ាងទូលំទូលាយទៅលើវិញ្ញាសាប្រឡង ដូចជា សង្គមវិទ្យា សេដ្ឋកិច្ច សាសនា ច្បាប់ ចិត្តវិទ្យា ការរៀបចំផែនការទីក្រុងនិងតំបន់ ទីផ្សារ តន្ត្រី និងការកម្សាន្តក្នុង*

ចំណោមមុខវិជ្ជាដទៃទៀត។ ជាទូទៅ ការពេញចិត្តក្នុងការយល់ឃើញចំពោះអ្វីមួយ គឺមានលក្ខណៈជាប្រធានវិស័យភាព និងគុណតម្លៃ ព្រោះវាផ្អែកលើស្តង់ដារដែលបានកំណត់ (Sirgy,ឆ្នាំ២០១២)។ការពេញចិត្តក្នុងការសិក្សា អាស្រ័យលើកត្តានានាដែលជះឥទ្ធិពលដល់។ការណ៍នេះ ក្នុងបរិបទនៅកម្ពុជាក៏មានការសិក្សាមួយធ្វើឡើងដើម្បីកំណត់នូវកត្តាជះឥទ្ធិពលដែលនាំឱ្យសិស្សថ្នាក់ទី១០រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រដែរ (សួរ ម៉ាយូណែត និងក្រុម, ២០២២)។ តែការសិក្សានេះ ផ្តោតតែលើសិស្សសិក្សានៅថ្នាក់ទី១០ប៉ុណ្ណោះ។

ក្នុងការសិក្សា«ការប្រៀបធៀបកម្រិតនៃការពេញចិត្តចំពោះមុខវិជ្ជាសិក្សារបស់សិស្សមធ្យមសិក្សា៖ ការស្រាវជ្រាវបឋម» នេះ អ្នកស្រាវជ្រាវ មានគោលបំណងប្រៀបធៀបកម្រិតនៃកត្តាការពេញចិត្តមុខវិជ្ជាសិក្សារបស់សិស្សមធ្យមសិក្សា រវាងមុខវិជ្ជាសង្គម និងវិទ្យាសាស្ត្រ។

## ២.កត្តាជះឥទ្ធិពលដល់ការសិក្សារបស់សិស្សានុសិស្ស

ការសិក្សាដែលទទួលបានជោគជ័យ គឺអាស្រ័យលើកត្តាផ្សេងៗ។ សិស្សដែលពូកែក្នុងការសិក្សា តែងតែរៀបចំផែនការ ឬគោលដៅសម្រាប់អនាគតរបស់ពួកគេ។ ដើម្បីកំណត់គោលដៅ អ្នកសិក្សាចាំបាច់ត្រូវពិចារណាលើអ្វីដែលចង់សម្រេចបាន កន្លែងដែលត្រូវស្វែងរក និងលក្ខខណ្ឌដែលត្រូវធ្វើ ដើម្បីបន្តក្តីសុបិន និងគោលដៅទាំងនោះ។ យោងតាម អេលិន ដោច និងក្រុម(២០២៤) បានសរសេរកំណត់គោលដៅដោយមានធាតុក្នុងការកំណត់គោលដៅជាក់លាក់។ ពិតណាស់ ធនធានមនុស្ស ជាកម្លាំងយ៉ាងសំខាន់ សម្រាប់ការអភិវឌ្ឍសង្គមជាតិឱ្យបានជោគជ័យ។ គោលដៅចម្បងផែនការអភិវឌ្ឍសង្គមសេដ្ឋកិច្ច គឺរៀបចំប្រជាជនយើងឱ្យក្លាយទៅជាពលរដ្ឋពេញលេញ (ក្រសួងអប់រំ យុវជននិងកីឡា,២០១៨)។ ការណ៍នេះ មានន័យថា ក្រសួង បានកំណត់គោលដៅច្បាស់លាស់។ តែបើយោងតាមNguyen

(២០២២) បានសិក្សាពីកត្តាជះឥទ្ធិពលដល់ការពេញចិត្តរបស់និស្សិតនៅសាកលវិទ្យាល័យដោយផ្តោតលើ គុណភាពនៃការបង្រៀន រចនាសម្ព័ន្ធវគ្គសិក្សា បរិស្ថានសិក្សា ការឆ្លើយតបរបស់គ្រូបង្រៀន និងការរំពឹងទុករបស់និស្សិតៗ ទាក់ទងនឹងចំណុចនេះ ការពេញចិត្តរបស់សិស្សក៏ផ្តោតលើកត្តាផ្សេងទៀតដែរ ដូចជា ទីតាំង ពាក្យសម្តី គន្លងអាជីព បរិក្ខារសិក្សា កេរ្តិ៍ឈ្មោះ ការផ្តល់ការអប់រំ និងភក្តីភាព (P.Venkateswarlu et al.,២០២០) ដូចមានក្នុងរូបភាពទី១ខាងក្រោម៖




*រូបភាពទី១៖ គំរូគ្របខណ្ឌបញ្ញត្តិនៃការពេញចិត្តរបស់សិស្ស* (P.Venkateswarlu et al.,២០២០)

បើយោងតាម Roselainy (២០១២) បានធ្វើការកំណត់កត្តាជះឥទ្ធិពលដល់ឥរិយាបថសិក្សារបស់សិស្ស ចំនួន៤ផ្នែក៖ ១).ចំណេះដឹងពីមុន ២).ការលើកទឹកចិត្ត ៣).ឱកាសដើម្បីរៀន និង៤).ឧបសគ្គចំពោះការផ្លាស់ប្តូរសិស្សៗ តែបើតាមការ

សិក្សាមួយទៀតបង្ហាញថា កត្តាជះឥទ្ធិពលដល់ដំណើរការនៃការសិក្សា រួមមាន ៨ផ្នែក៖ ១).ការលើកទឹកចិត្ត ២).សមត្ថភាពយល់ដឹង ៣).អារម្មណ៍ ៤).បរិយាកាស ៥).រចនាប័ទ្មសិក្សា ៦).ចំណេះដឹងពីមុន ៧).សុខភាពរាងកាយ និង៨).ឥទ្ធិពលសង្គម ឬវប្បធម៌(ដកស្រង់ចេញពីគេហទំព័រ៖ https://www.rawatpublicschool.com/blog/essential-factors-affecting-the-learning-process)។ តែបើយោងតាម Xiaowei (២០២១) បានសិក្សាវប្បធម៌ថ្នាក់រៀននិងការតភ្ជាប់របស់សិស្សក្នុងការសិក្សា ដោយផ្តោតលើ៦ផ្នែក៖ ១).អាកប្បកិរិយា ២).សង្គម ៣).ការសិក្សា ៤).ចិត្តរំភើប ៥).ការយល់ដឹង និង៦).ភ្នាក់ងារអប់រំដូចមានក្នុងរូបភាពទី២ខាងក្រោម៖




រូបភាពទី២៖ តំណភ្ជាប់របស់សិស្ស ( Xiaowei ,២០២១)

## ៣.កត្តាចម្បងជះឥទ្ធិពលដល់ការពេញចិត្តក្នុងការសិក្សារបស់សិស្សានុសិស្ស

*យោងតាមការលើកឡើងខាងលើ ឃើញមានកត្តាជាច្រើនជះឥទ្ធិពលដល់ការពេញចិត្តក្នុងការសិក្សារបស់សិស្ស និស្សិត។ ប៉ុន្តែនៅក្នុងការសិក្សានេះ អ្នកស្រាវជ្រាវ បានសំយោគជា៥ផ្នែកសំខាន់គឺ ១).ផ្នែករចនាសម្ព័ន្ធសាលា ២).ផ្នែកអន្តរកម្មរបស់អ្នកសិក្សា ៣).ផ្នែកការចូលរួមរបស់សិស្ស ៤).ផ្នែកការពេញចិត្តរបស់សិស្ស និង៥).ផ្នែកការយល់ដឹងមេរៀនរបស់សិស្ស។ ការណ៍នេះ ការស្រាវជ្រាវ បឋមផ្តោតតែលើកត្តានៃការពេញចិត្តមុខវិជ្ជាសិក្សាតែប៉ុណ្ណោះ ហើយមានគោលបំណងប្រៀបធៀបពីកម្រិតនៃការពេញចិត្តលើមុខវិជ្ជាសិក្សាផ្នែកសង្គម និងផ្នែកវិទ្យាសាស្ត្ររបស់សិស្សមធ្យមសិក្សា។*

*ចំពោះការសិក្សានេះ អ្នកស្រាវជ្រាវបានកំណត់ឧបករណ៍ស្រាវជ្រាវជាកម្រងសំណួរចំនួន២ផ្នែក៖ ១).ផ្នែកស្ថានភាពប្រជាសាស្ត្ររបស់សិស្ស និង២).ផ្នែកការយល់ដឹងលើការពេញចិត្តក្នុងការសិក្សារបស់សិស្ស។ ស្ថានភាពប្រជាសាស្ត្ររបស់សិស្ស បានបង្ហាញដូចខាងក្រោម៖*

### ៣.១-ព័ត៌មានទូទៅ




*ក្រាបទី១.ភេទរបស់អ្នកឆ្លើយសំណួរ*

*តាមក្រាបទី១ បង្ហាញថា អ្នកចូលរួមឆ្លើយសំណួរ មានចំនួនN=១០៥នាក់ ក្នុងនោះ*

មានសិស្សស្រីចំនួន៦១នាក់ ស្មើនឹង ៥៨,១០% និងសិស្សប្រុសចំនួន៤៤នាក់ ស្មើនឹង៤១,៩០%។




ក្រាបទី២៖ អាយុនៃអ្នកឆ្លើយសំណួរ

តាមក្រាបទី២ បង្ហាញថា អ្នកចូលរួមឆ្លើយសំណួរ មានចំនួនN=១០៥នាក់ ក្នុងនោះសិស្សចន្លោះអាយុ១២-១៤ មាន១៩នាក់ ស្មើនឹង១៨,១០% ហើយសិស្សចន្លោះអាយុ១៥-១៨ មាន៧៩នាក់ ស្មើនឹង ៧៥,២០% និងសិស្សមានអាយុចាប់ពី១៩ឆ្នាំឡើងមាន៧នាក់ ស្មើនឹង៦,៧០%។




ក្រាបទី៣៖ កម្រិតថ្នាក់នៃអ្នកឆ្លើយសំណួរ

តាមក្រាបទី៣ បង្ហាញថា អ្នកចូលរួមឆ្លើយសំណួរ មានចំនួនN=១០៥នាក់ ក្នុងនោះសិស្សរៀនថ្នាក់ទី៧-៩ មានចំនួន២១នាក់ស្មើនឹង២០% ហើយសិស្សរៀនថ្នាក់ទី១០-១១មានចំនួន៦៩នាក់ ស្មើនឹង៦៥,៧០% និងសិស្សរៀនទី១២មានចំនួន១៥នាក់ ស្មើនឹង១៤,៣០%។

## ៣.២-លទ្ធផលស្រាវជ្រាវ

លទ្ធផលនៃការសិក្សានេះ ជារួមមានកម្រិតខ្ពស់គ្រប់ផ្នែកទាំងអស់។ ការពេញចិត្ត ជាផ្នែកដែលមានកម្រិតខ្ពស់ជាងគេដូចខាងក្រោម៖

### ៣.២.១-ការពេញចិត្តលើមុខវិជ្ជា




*ក្រាបទី៤៖ ការពេញចិត្តមុខវិជ្ជាផ្នែកសង្គម*

តាមក្រាបទី៤ខាងលើ បង្ហាញថា សិស្សភាគច្រើន ពេញចិត្តខ្លាំងបំផុតក្នុងការសិក្សាមុខវិជ្ជាសង្គមដោយមានសិស្សចំនួន៣២នាក់ ស្មើនឹង៣០,៥០% ក្នុងចំណោមសិស្សបានចូលរួមឆ្លើយមានចំនួន N=១០៥ ។




*ក្រាបទី៩៖ ការពេញចិត្តមុខវិជ្ជាផ្នែកវិទ្យាសាស្ត្រ*

*តាមក្រាបទី៩ខាងលើនេះ បង្ហាញថា សិស្សដែលបានចូលរួមឆ្លើយសំណួរមាន ចំនួន N=១០៥នាក់ ដោយក្នុងនោះសិស្ស ពេញចិត្តខ្លាំងបំផុតលើមុខវិជ្ជាវិទ្យាសាស្ត្រ មានចំនួន២២នាក់ ស្មើនឹង២១%។*

### ៣.២.២-ប្រៀបធៀបភាពពេញចិត្តក្នុងការសិក្សារបស់សិស្សតាមមុខវិជ្ជា

*បើយោងតាមក្រាបទី៨ និងក្រាបទី៩ ខាងលើ អាចកំណត់បានថា សិស្សមាន ការពេញចិត្តខ្លាំងលើមុខវិជ្ជាសង្គមស្មើ ៣០,៥០% ច្រើនជាងមុខវិជ្ជាវិទ្យាសាស្ត្រ ស្មើ២១%។*

## ៤-សេចក្តីសន្និដ្ឋាន

*ឆ្លងតាមការសិក្សាមកខាងលើ បង្ហាញថា ការសិក្សារបស់សិស្សមធ្យមសិក្សា មានសារៈសំខាន់ណាស់ ហើយមានកត្តាជាច្រើនជះឥទ្ធិពលដល់ការសិក្សារបស់ពួកគេ។ ការពេញចិត្តលើមុខវិជ្ជាណាមួយជាកត្តាគន្លឹះមួយ ដើម្បីសម្រេចបានលទ្ធផលដែលជាគោលដៅនៃការអប់រំដែលបានកំណត់ដោយរដ្ឋាភិបាល។ លទ្ធផលនៃការសិក្សារបស់សិស្សមធ្យមសិក្សា ជាជំហានចាំបាច់ក្នុងការឈានទៅកាន់ការសិក្សានៅឧត្តមសិក្សាតាមជំនាញនីមួយៗ*

ដែលកើតពីការពេញចិត្ត លទ្ធភាព និង សមត្ថភាពរបស់សិស្សានុសិស្ស។

## ឯកសារយោង

**ភាសាខ្មែរ**

ក្រុមប្រឹក្សាជាតិភាសាខ្មែរ .(២០២២).វចនានុក្រមខ្មែរ។ ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា។

ហៃយ ចម្រង.(២០១៩).ទស្សនៈយល់ឃើញរបស់មាតាបិតាក្នុងការបញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យសិក្សាអាយុបី បួន និងប្រាំឆ្នាំ(ករណីសិក្សាះសាលាមត្តេយ្យ៨មីនានៅរាជធានីភ្នំពេញ)។និក្ខេបបទបរិញ្ញាបត្រជាន់ខ្ពស់។ ការផ្សាយរបស់វិទ្យាស្ថានជាតិអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា .(២០២២).មធ្យមសិក្សាចំណេះទូទៅ។ ស្រង់ពីគេហទំព័រ https://moeys.gov.kh/kh/general-secondary-education

ក្រសួងអប់រំ យុវជន និងកីឡា .(២០១៨).សៀវភៅវិធីសាស្ត្របង្រៀនសម្រាប់អនុវត្តគ្រប់មុខវិជ្ជាឯកទេស។

សូរ ម៉ាយូណែត ,គុជ សំអ៊ែល, គឹម មង្គល,ប៉ែនវន្ថា ,កូវ ធារី,និងឥន រិទ្ធី(២០២២)កត្តាជះឥទ្ធិពលឱ្យសិស្សថ្នាក់ទី១០រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រ។អត្ថបទស្រាវជ្រាវប្រតិបត្តិ។ ការផ្សាយកាលិកបត្រអប់រំកម្ពុជា។

**ភាសាអង់គ្លេស**

Elehba, Emmanuel. O. Folorunso &DAH, Paul D.(2017).SATISFACTION. Department of Urban and Regional Planning School of Environmental Planning The Federal Polytechnic, P.M.B. 1037Idah, Kogi State.

Nguyen N. N.(2022). Factors Affecting Student Satisfaction When Studying At A University In Vietnam. Journal of Positive School Psychology, 2022, Vol. 6, No. 7, 2349-2355

Roselainy A. R., John H. M., Yudariah M. Y. (2012).Factors Affecting Students´ Change of Learning Behaviour,Procedia - Social and Behavioral Sciences 56 ( 2012 ) 213 – 222

P. Venkateswarlu, S. Malaviya, M. Vinay.(2020). Determinants of the Satisfaction of Students Studying in Private Universities—Application of Kano Model

Sirgy, M. J. (2012). The Psychology of Quality of life: Hedonic Well-Being, Life Satisfaction and Eudaimonia. Second Edition. Social Indicator Research Series 50. Springer.

Xiaowei Tu .(2021). The Role of Classroom Culture and Psychological Safety in EFL Students´ Engagement. Published: 29 September 2021, doi: 10.3389/fpsyg.2021.760903